**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨៤៤
ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ ៦៣៩ ម.ឧ
ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ១៧២
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌ
លេខ ៣២/០៣ ក្រ២ "ច"
ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២

# សាលក្រមព្រហ្មទណ្ឌ
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ
នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៩ ព្រឹក
ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ក្រុមប្រឹក្សាជំនុំជម្រះ
លោក ក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងជំនុំជម្រះលេខ ១៧២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ដែលត្រូវបានបញ្ជូនមកតុលាការជំនុំជម្រះ តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរលេខ ០៤៧ ដ.ដ.ស/៣/២២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ។

**១. ជនជាប់ចោទ និងវត្ថុចាប់យក**

១.១. ជនជាប់ចោទ

(១). ឈ្មោះ [redacted] ហាម៉ាត់ ភេទប្រុស កើតឆ្នាំ១៩៨៩ (អាយុ៣២ឆ្នាំ)[1] ជនជាតិខ្មែរឥស្លាម មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រះសីហនុ និងមាន

[1] អាយុសរសេរនៅក្នុងសញ្ញា ( ) សំដៅលើអាយុដែលជនជាប់ចោទត្រូវបានសង្ស័យថាប្រព្រឹត្តបទល្មើស ឬរងចោទប្រកាន់



Scanned with CamScanner

អាសយដ្ឋាននៅភូមិ[redacted] ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ[redacted] ខនី មានកូន ២នាក់ ឪពុកឈ្មោះ[redacted]ម៉ឺត (រស់) ម្តាយឈ្មោះ[redacted] ម៉ៃណះ(រស់) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។

ជនជាប់ចោទរូបនេះត្រូវបានឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៣៤ តព/២១ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ ។

ជននេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៧ ចំនុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ជនជាប់ចោទមានលោកមេធាវី [redacted] មានការិយាល័យឈ្មោះក្រុមមេធាវីសែនសុខ មានអាសយដ្ឋានផ្ទះលេខ ១២៨ bis ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ និងលោក [redacted] មានការិយាល័យឈ្មោះ ក្រុមហ៊ុនមេធាវី ខេមជីន មានអាសយដ្ឋាន អគារ DIAMON TWIN TOWER ជាន់ទី១១ ផ្លូវសុកមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

(២). ឈ្មោះ[redacted] នឿន ភេទប្រុស កើតឆ្នាំ១៩៩០ (អាយុ៣១ឆ្នាំ) ជនជាតិខ្មែរ មុខរបរជាងឈើ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រះសីហនុ និងមានអាសយដ្ឋាននៅភូមិបឹ[redacted] ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ[redacted] នី (លែងលះ)គ្មានកូន ឪពុកឈ្មោះ[redacted] មួន (ស្លាប់) ម្តាយឈ្មោះ[redacted]សាត់ (ស្លាប់) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។

ជនជាប់ចោទរូបនេះត្រូវបានឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៣៥ តព/២១ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ ។

ជននេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.២. វត្ថុចាប់យក

វត្ថុចាប់យក ដែលបានដកហូតពីជនជាប់ចោទ និងជាកម្មវត្ថុនៃការជំនុំជម្រះ រួមមាន ៖

ក. ដកហូតពីជនជាប់ចោទឈ្មោះ[redacted] ហាម៉ាត់

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់សុទ្ធ ៣៤៩,១២ ក្រាម
- ថ្នាំគ្រាប់ (WY) ចំនួន ១គ្រាប់កន្លះ ទម្ងន់សុទ្ធ ០,១៥ ក្រាម

CH

- ទូរស័ព្ទដៃចំនួន ១គ្រឿង ម៉ាក OPPO ពណ៌ស
- កាំភ្លើងកែច្នៃចំនួន ១ដើម ។

ខ. ដកហូតពីជនជាប់ចោទឈ្មោះ [redacted] នឿន

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់ ០,១២ ក្រាម
- ទូរស័ព្ទដៃចំនួន ២ គ្រឿង (ម៉ាក IPHONE XS MAX ពណ៌ទឹកមាស និងម៉ាក NOKIA ពណ៌ខ្មៅ) ។

## ២. អង្គហេតុដែលប្ដឹងមកតុលាការ

កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៣ និង០០នាទី ស្ថិតនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្លាំងអធិការដ្ឋាននគរបាលស្រុកព្រៃនប់ សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសាមគ្គី បានបង្ក្រាបករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយករណីដោយធ្វើការឃាត់ខ្លួនបានឈ្មោះ [redacted] ហាម៉ាត់ ដកហូតបានម្សៅសថ្លាសង្ស័យជាសារធាតុញៀន ប្រភេទមេតំហ្វេតាមីនទឹកកក (ICE) ចំនួន ១កញ្ចប់ ទម្ងន់ ៣៤៩,១២ ក្រាម , ថ្នាំគ្រាប់សញ្ញា WY ចំនួន ១ គ្រាប់កន្លះ ទម្ងន់ ០,១៥ ក្រាម និងទូរស័ព្ទដៃ ចំនួន ១ គ្រឿង និងឈ្មោះ [redacted] នឿន ដកហូតបានម្សៅសថ្លាសង្ស័យជាសារធាតុញៀន ប្រភេទមេតំហ្វេតាមីនទឹកកក (ICE) ចំនួន ១ កញ្ចប់ ទម្ងន់ ០,១២ ក្រាម និងទូរស័ព្ទដៃ ចំនួន ២ គ្រឿង ។

## ៣. ដំណើរការនៃកិច្ចពិភាក្សាដេញដោល

### ៣.១. បញ្ហាកិច្ចនីតិវិធី

ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ , ឈ្មោះ [redacted] នឿន និងលោកមេធាវី [redacted] មានវត្តមាននៅក្នុងកិច្ចពិភាក្សាដេញដោល ។ ជនជាប់ចោទ មេធាវី និងតំណាងអយ្យការមិនមានការជំទាស់ទៅនឹងបញ្ហានីតិវិធីណាមួយទេ និងបានស្នើសុំតុលាការបន្តកិច្ចពិភាក្សាដេញដោលទៅតាមនីតិវិធីច្បាប់ ។ តុលាការសម្រេចបន្តដំណើរការនៃកិច្ចពិភាក្សាដេញដោល ។

### ៣.២. ចម្លើយ ឬអំណានចម្លើយរបស់ភាគី និងកិច្ចផ្សេងទៀតក្នុងការពិភាក្សាដេញដោល

ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ បានឆ្លើយថា ៖ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនជាង ១ ឆ្នាំមកហើយ និងធ្លាប់បានលក់គ្រឿងញៀនទើបតែជាង ២ ខែទេ ។ នៅថ្ងៃកើតហេតុនោះ ខ្លួនបានជិះម៉ូតូឌុបទៅផ្ទះរបស់ឈ្មោះ [redacted] នឿន ដោយសារឈ្មោះនេះរកទិញគ្រឿងញៀនពីខ្លួន ។ លុះពេលនៅដល់ផ្ទះឈ្មោះ [redacted] នឿន ក៏បាននាំគ្នាប្រើប្រាស់គ្រឿងញៀន ។ ឈ្មោះ [redacted] នឿន ទិញគ្រឿងញៀនពីខ្លួនដើម្បីយកទៅប្រើប្រាស់ និងធ្លាប់ទិញគ្រឿងញៀនពីខ្លួន ២ ទៅ ៣ ដងដែរ ។ គ្រឿងញៀនដែលសមត្ថកិច្ច

ឆែកឆេរឃើញនៅផ្ទះខ្លួន គឺជារបស់ខ្លួន ដែលបានទិញពីឈ្មោះ ស្វា ពីភ្នំពេញ ។ ខ្លួនធ្លាប់ទិញពីឈ្មោះ ស្វា នេះចំនួន ២ ដងមកហើយ ។

ជនជាប់ចោទឈ្មោះ [redacted] នឿន បានឆ្លើយថា ៖ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេល ១ ឆ្នាំមកហើយ ។ នៅថ្ងៃកើតហេតុ ខ្លួនបានប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] ហាម៉ាត់ និងកូនជាង ២ នាក់ទៀត ។ ពេលប្រើប្រាស់នោះ សមត្ថកិច្ចក៏ចុះមកឃាត់ពួកខ្លួនតែម្តង ។ ខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ហាម៉ាត់ ដោយទិញក្នុងតម្លៃពី ៣០.០០០ រៀល ទៅ ៤០.០០០ រៀល ហើយពេលខ្លះទិញដល់ ៣០០.០០០ រៀល ។ ខ្លួនមិនធ្លាប់លក់គ្រឿងញៀននោះទេ តែធ្លាប់ទិញគ្រឿងញៀនឱ្យកូនជាងប្រើប្រាស់ដែរ ហើយពេលឱ្យកូនជាងប្រើប្រាស់ ខ្លួនមិនដែលយកប្រាក់ពីពួកគាត់នោះទេ ។

លោក [redacted] ពិសិដ្ឋ សាក្សីជាសមត្ថកិច្ច បានឆ្លើយថា ៖ ឈ្មោះ [redacted] ហាម៉ាត់ និងឈ្មោះ [redacted] នឿន ជាមុខសញ្ញាជួញដូរគ្រឿងញៀន ដែលសមត្ថកិច្ចតាមយូរមកហើយ ។ នៅថ្ងៃដែលសមត្ថកិច្ចចុះទៅបង្ក្រាបនោះឈ្មោះ [redacted] ហាម៉ាត់ នៅផ្ទះរបស់ឈ្មោះ [redacted] នឿន ហើយពួកគេកំពុងប្រើប្រាស់គ្រឿងញៀននៅផ្ទះនោះ ។ ពេលឃាត់ខ្លួនឈ្មោះ [redacted] នឿន ដកហូតបានគ្រឿងញៀនចំនួន ០,១២ ក្រាម និងបន្តទៅឆែកឆេរផ្ទះរបស់ឈ្មោះ [redacted] ហាម៉ាត់ ឆែកឆេរឃើញគ្រឿងញៀនជិត ៣០០ ក្រាម ។

លោកស្រីក្រឡាបញ្ជី [redacted] បានអានសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍លេខ ២១០ រ.ប.ក/២១ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន ។

### ៣.៣. ការកត់សម្គាល់របស់ភាគី និងសេចក្តីសន្និដ្ឋាន ក្រោយពីកិច្ចពិភាក្សាដេញដោល

លោកព្រះរាជអាជ្ញារង [redacted] បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ក្រោយពីស្តាប់ចម្លើយរបស់ជនជាប់ចោទ សាក្សីជាសមត្ថកិច្ច និងពិនិត្យភស្តុតាងក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ និងបញ្ជូនមកតុលាការជំនុំជម្រះមែន ហើយអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ គឺជាបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៧ ចំណុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំពោះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន គឺជាបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ និងសូមឱ្យផ្ទៀងផ្ទាត់លើបរិមាណជាតុសុទ្ធនៃគ្រឿងញៀន ។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ និងឈ្មោះ [redacted] នឿន បានធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ កូនក្តីខ្លួនឈ្មោះ [redacted] ហាម៉ាត់ និងឈ្មោះ [redacted] នឿន បានឆ្លើយសារភាពពីអំពើរបស់ពួកគាត់ហេតុនេះខ្លួនស្នើសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ។

ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ បានធ្វើការកត់សម្គាល់ថា ៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួន ។

ជនជាប់ចោទឈ្មោះ [redacted] នឿន បានធ្វើការកត់សម្គាល់ថា ៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួន ។

## ៤. សំអាងហេតុ

### ៤.១. បញ្ហាពិរុទ្ធភាព

(១). តាមដីកាដំណោះស្រាយលេខ ០៤៧ ដ.ដ.ស/៣/២២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ មកតុលាការដើម្បីធ្វើការជំនុំជម្រះពាក់ព័ន្ធនឹងបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៧ ចំនុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំណែកឯជនជាប់ចោទឈ្មោះ [redacted] នឿន បញ្ជូនមកតុលាការដើម្បីធ្វើការជំនុំជម្រះពាក់ព័ន្ធនឹងបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

(២). ផ្អែកតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣៥១៥៧/២២ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ និងលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣៥១៥៨/២២ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ តុលាការពិនិត្យឃើញថា វត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀន ដែលបានដកហូតពីជនជាប់ចោទឈ្មោះ ម៉ើត ហាម៉ាត់ និងឈ្មោះ [redacted] នឿន នោះគឺជាគ្រឿងញៀន ដែលមានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ។ ភស្តុតាងក្នុងចំណុចនេះគឺគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ និងឈ្មោះ [redacted] នឿន ពីបទល្មើសគ្រឿងញៀនខាងលើ ប្រសិនបើជនជាប់ចោទបានប្រព្រឹត្តអំពើដូចអង្គហេតុដែលប្តឹងមកតុលាការជំនុំជម្រះមែន ។

(៣). ក្នុងរឿងនេះ សាក្សីជាសមត្ថកិច្ចបានផ្តល់ចម្លើយក្នុងខ្លឹមសារថា ជនជាប់ចោទទាំងពីរនាក់គឺមុខសញ្ញាជួញដូរគ្រឿងញៀន ហើយនៅកើតហេតុនោះ ខណៈពេលជនជាប់ចោទប្រើប្រាស់គ្រឿងញៀននៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន នោះ សមត្ថកិច្ចបានចុះទៅ និងឆែកឆេរផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន រកឃើញគ្រឿងញៀន ចំនួន ០,១២ ក្រាមទៀត បន្ទាប់មកសមត្ថកិច្ចបានបន្តទៅឆែកឆេរផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ រកឃើញគ្រឿងញៀនជិត ៣០០ ក្រាមបន្ថែមទៀតដែរ ។ បើផ្អែកតាមចម្លើយរបស់សមត្ថកិច្ច និងវត្ថុចាប់យកជាគ្រឿងញៀនដែលសមត្ថកិច្ចឆែកឆេររក



Scanned with CamScanner

ឃើញនៅផ្ទះរបស់ជនជាប់ចោទពីនាក់នោះ វាបង្កើតជាហេតុផលគ្រប់គ្រាន់ឱ្យតុលាការជឿកជាក់ថា ជនជាប់ចោទទាំងពីនាក់ពិតជាបានប្រព្រឹត្តអំពើប្រើប្រាស់ និងរក្សាទុកគ្រឿងញៀនដោយខុសច្បាប់មែន ។ បន្ថែមនេះ បើយោងតាមបរិមាណនៃគ្រឿងញៀន ចំនួនជិត ៣០០ ក្រាម ដែលរកឃើញនៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ គឺគ្រប់គ្រាន់ដាក់បន្ទុកលើកជនជាប់ចោទរូបនេះពីជួញដូរគ្រឿងញៀនដោយខុសច្បាប់ដែរ ទោះបីជាជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ មិនសារភាពក៏ដោយ ។ ដោយឡែកដោយសារតែគ្រឿងញៀនដែលរកឃើញពីផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ដែលមានចំនួន ០,១៥ ក្រាមនោះ វាបង្កើតជាការសង្ស័យមួយថា តើជនជាប់ចោទរូបនេះជាមុខសញ្ញជួញដូរគ្រឿងញៀន ឬបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនដែរ ឬទេ ?

(៤). ចំពោះជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ជនជាប់ចោទរូបនេះបានសារភាពទទួលស្គាល់ថា "ខ្លួនបានប្រើប្រាស់គ្រឿងញៀនជាមួយនឹងឈ្មោះ [redacted] នឿន នៅផ្ទះរបស់គាត់ និងបានទិញគ្រឿងញៀនពីឈ្មោះ ស្នា នៅភ្នំពេញមកទុកលក់បន្តមែន" ។ ចម្លើយសារភាពនេះគឺសង្វាក់ទៅនឹងចម្លើយដាក់បន្ទុករបស់សាក្សីជាសមត្ថកិច្ច និងរបាយការណ៍លេខ ២១០ រ.ប.ក/២១ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ក៏ដូចជាការឆែកឆេររកឃើញគ្រឿងនៅផ្ទះរបស់ឈ្មោះ [redacted] ហាម៉ាត់ ដែរ ។ ភស្តុតាងទាំងនេះគឺគ្រប់គ្រាន់អាចបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ពិតជាពាក់ព័ន្ធនឹងបទល្មើសជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់ ដូចអង្គហេតុដែលប្ដឹងមកតុលាការជំនុំជម្រះមែន ។

(៥). ដោយឡែកជនជាប់ចោទឈ្មោះ [redacted] នឿន បានឆ្លើយសារភាពទាក់ទងការប្រើប្រាស់គ្រឿងញៀន និងក៏ទទួលស្គាល់នូវការឆែកឆេររកឃើញគ្រឿងញៀនចំនួន ០,១២ ក្រាមនៅផ្ទះរបស់ខ្លួនដែរ ប៉ុន្តែជនជាប់ចោទរូបនេះបដិសេធថា "ខ្លួនមិនបានធ្លាប់លក់គ្រឿងញៀននោះទេ" ។ ចម្លើយសារភាពរបស់ជនជាប់ចោទរូបនេះគឺចម្លើយទៅចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀននៅថ្ងៃកើតហេតុនោះ ហើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់សមត្ថកិច្ច ក៏ដូចជាការរកឃើញគ្រឿងញៀនចំនួន ០,១២ ក្រាម ជាក់ស្ដែងនៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ដែរ ។ ភស្តុតាងទាំងនេះគឺគ្រប់គ្រាន់អាចបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] នឿន ពិតជាពាក់ព័ន្ធនឹងការរក្សាទុក និងប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់មែន ។

(៦). បន្ថែមពីនេះ តុលាការក៏យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] នឿន ក៏ពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀនដែរ បើយោងតាមចម្លើយដាក់បន្ទុករបស់សាក្សីសមត្ថកិច្ច ព្រោះពុំមានហេតុផលដែលសមត្ថកិច្ចត្រូវឆ្លើយដាក់បន្ទុកលើជនជាប់ចោទ ប្រសិនបើជនជាប់ចោទមិនមែនជាអ្នកលក់គ្រឿងញៀននោះ ។ មួយវិញទៀត តុលាការមិនជឿកជាក់លើចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន នោះទេ ហើយក៏មិនជឿជាក់លើចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ដែលឆ្លើយថា "ឈ្មោះ [redacted] នឿន ទិញគ្រឿងញៀនពីខ្លួនដើម្បីទៅប្រើប្រាស់" នោះដែរ ព្រោះតុលាការយល់ឃើញថា

ជនជាប់ចោទទាំងពីរមានទំនាក់ទំនងស្និលស្នាលនឹងគ្នា រហូតដល់មានការប្រើប្រាស់គ្រឿងញៀនជាមួយគ្នានៅផ្ទះរបស់ឈ្មោះ [redacted] នឿន ដែរ ហើយជនជាប់ចោទឈ្មោះ [redacted] នឿន ក៏បានរក្សាទុកគ្រឿងញៀននៅផ្ទះខ្លួនឯងដែរ ។ លើសពីនេះទៅទៀតនោះ បើតាមការពិនិត្យមើលចម្លើយរបស់ជនជាប់ចោទទាំងពីរនៅគ្រប់ដំណាក់នោះ តុលាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] នឿន ធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ហាម៉ាត់ បីទៅបួនដងមកហើយ ហើយតម្លៃ ឬចំនួននៃការទិញនោះគឺអាចជាការទិញដើម្បីលក់បន្តមិនមែនត្រឹមតែជាការប្រើប្រាស់ ។ ដោយហេតុផលទាំងនេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] នឿន ពិតជាពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀនដូចអង្គហេតុដែលប្តឹងមកតុលាការមែន ។

(៧). ជនជាប់ចោទជានីតិជន ដែលមានបុគ្គលិកលក្ខណៈគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យលទ្ធផល និងផលប៉ះពាល់ចេញពីអំពើរបស់ខ្លួនផងដែរ ។ ជនជាប់ចោទពិតជាដឹងថា ការរក្សា លក់ និងការប្រើប្រាស់គ្រឿងញៀនគឺជាអំពើល្មើសច្បាប់ ប៉ុន្តែជនទាំងនេះនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ។ អំពើរបស់ជនជាប់ចោទនេះក៏បង្កជាផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម ដែលច្បាប់បានកំណត់ថាជាបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

(៨). ជារួម តុលាការយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៧ ចំនុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] នឿន ពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតុលាការគប្បីពិចារណា និងសម្រេចអំពីផ្តន្ទាទោសលើជនជាប់ចោទទាំងពីរទៅតាមបញ្ញត្តិច្បាប់ និងសម្រេចអំពីវត្ថុចាប់យកផងដែរ ។

## ៤.២. ការផ្តន្ទាទោស និងវត្ថុចាប់យក

(១). តំណាងអយ្យការបានស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។ នៅពេលសវនាការ ជនជាប់ចោទទាំងពីរនាក់បានស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ពួកខ្លួន ។ ក្នុងរឿងនេះ គ្រឿងញៀនដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ចំនួន ២ កញ្ចប់ ដោយកញ្ចប់ទី១ ទម្ងន់ ៣៤៩,១២ ក្រាម និងមានសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានបរិមាណសារធាតុញៀន គិតជាភាគរយនៃទម្ងន់ ៧៩,៤៧ % ដូចនេះមបរិមាណសុទ្ធនៃគ្រឿងញៀន ទម្ងន់ ២៧៧,៤៤ ក្រាម (តារាងទី២) ។ កញ្ចប់ទី ២ ទម្ងន់ ០,១៥ ក្រាម និងមានសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានបរិមាណសារធាតុញៀន គិតជាភាគរយនៃទម្ងន់ ៨,៣៩ % ដូចនេះមបរិមាណសុទ្ធនៃគ្រឿងញៀន ទម្ងន់ ០,០១



Scanned with CamScanner

ក្រាម (តារាងទី២) ។ ចំពោះគ្រឿងញៀនដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ចំនួន ១ កញ្ចប់ ទម្ងន់ ០,១២ ក្រាម និងមានសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានបរិមាណសារធាតុញៀន គិតជាភាគរយនៃទម្ងន់ ៧៩,៤៧ % ដូចនេះបរិមាណសុទ្ធនៃគ្រឿងញៀន ទម្ងន់ ០,០៩ ក្រាម (តារាងទី២) ។

(២). ជារួម តុលាការយល់ឃើញថា ការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២០ (ម្ភៃ) ឆ្នាំ លើជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ និងផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ព្រមទាំងផ្តន្ទាទោសចំនួន ២ (ពីរ) ឆ្នាំ លើជនជាប់ចោទឈ្មោះ [redacted] នឿន គឺជួនល្មមទៅនឹងអំពើរបស់ជនជាប់ចោទម្នាក់ៗ និងការសារភាពរបស់ជនជាប់ចោទ ក៏ដូចជាផលប៉ះពាល់ដល់សង្គមដែលកើតឡើងពីអំពើរបស់ជនជាប់ចោទ ព្រមទាំងទម្ងន់នៃបរិមាណសុទ្ធនៃគ្រឿងញៀននៅក្នុងសំណុំរឿងនេះ ។

(៣). តុលាការយល់ឃើញថា គប្បីសម្រេចរឹបអូសវត្ថុចាប់យក ដូចខាងក្រោម ៖

ក. វត្ថុចាប់យកដកហូតពីជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់សុទ្ធ ៣៤៩,១២ ក្រាម
- ថ្នាំគ្រាប់ (WY) ចំនួន ១ គ្រាប់កន្លះ ទម្ងន់សុទ្ធ ០,១៥ ក្រាម
- ទូរស័ព្ទដៃចំនួន ១ គ្រឿង ម៉ាក OPPO ពណ៌ស
- កាំភ្លើងកែច្នៃចំនួន ១ ដើម ។

ខ. វត្ថុចាប់យកដកហូតពីជនជាប់ចោទឈ្មោះ [redacted] នឿន

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់ ០,១២ ក្រាម
- ទូរស័ព្ទដៃចំនួន ២ គ្រឿង (ម៉ាក IPHONE XS MAX ពណ៌ទឹកមាស និងម៉ាក NOKIA ពណ៌ខ្មៅ) ។

ព្រោះវត្ថុទាំងនោះជាសារធាតុញៀនញៀនខុសច្បាប់ និងជាឧបករណ៍ដែលជនជាប់ចោទបានប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទង ឬជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ។

## ៥. សេចក្តីសម្រេច

(១). ផ្តន្ទាទោសលើជនជាប់ចោទ ដូចខាងក្រោម ៖

ក. ដាក់ទោសពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ ភេទប្រុស កើតឆ្នាំ១៩៨៩ (អាយុ៣២ឆ្នាំ) ចំនួន ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៧ ចំណុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ. ដាក់ទោសពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] នឿន ភេទប្រុស កើតឆ្នាំ១៩៩០ (អាយុ ៣១ឆ្នាំ) ចំនួន ២ (ពីរ) ឆ្នាំ ពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបឹងរាំង ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៤ ចំនុច ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

(២). រឹបអូសវត្ថុចាប់យកដែលដកហូតពីជនជាប់ចោទ [redacted] ហាម៉ាត់ ដូចខាងក្រោម ៖

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់សុទ្ធ ៣៤៩,១២ ក្រាម
- ថ្នាំគ្រាប់ (WY) ចំនួន ១គ្រាប់កន្លះ ទម្ងន់សុទ្ធ ០,១៥ ក្រាម
- ទូរស័ព្ទដៃចំនួន ១គ្រឿង ម៉ាក OPPO ពណ៌ស
- និងកាំភ្លើងកែច្នៃចំនួន ១ ដើម ។

(៣). រឹបអូសវត្ថុចាប់យកដកហូតពីជនជាប់ចោទឈ្មោះ [redacted] នឿន រួមមាន ៖

- ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ១ កញ្ចប់ ទម្ងន់ ០,១២ ក្រាម
- និងទូរស័ព្ទដៃចំនួន ២ គ្រឿង (ម៉ាក IPHONE XS MAX ពណ៌ទឹកមាស និងម៉ាក NOKIA ពណ៌ខ្មៅ) ។

សាលក្រមនេះត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២២ ។ សាលក្រមនេះជាសាលក្រមចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហាម៉ាត់ និងឈ្មោះ [redacted] នឿន ។ ក្នុងករណីប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ១ (មួយ) ខែ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តព្រះសីហនុ, ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ បានឃើញ

**ក្រឡាបញ្ជី** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted]